**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ២១៤ អនក្រ.បក

**អនុក្រឹត្យ**

**ស្តីពី**

**ការកែសម្រួលផ្ទៃបឹងតាមោក (បឹងកប់ស្រូវ) ស្ថិតក្នុងរាជធានីភ្នំពេញ**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី ៣០ ខែមីនា ឆ្នាំ ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែសីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី ០៣ ខែសីហា ឆ្នាំ ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែវិច្ឆិកា ឆ្នាំ ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងនីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ០៣ ខែកុម្ភៈ ឆ្នាំ ២០១៦ ស្តីពីការកំណត់ផ្ទៃបឹងតាមោក (បឹងកប់ស្រូវ) ទំហំ ៣ ២៣៩,៧ ហិកតា ស្ថិតក្នុងរាជធានីភ្នំពេញ ជាសម្បត្តិសាធារណៈរបស់រដ្ឋ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

**សម្រេច**

**មាត្រា១ .-**

កាត់ផ្ទៃដីទំហំ ២៧ ៦៥៩ (ម្ភៃប្រាំពីរពាន់ប្រាំមួយរយហាសិបប្រាំបួន) ម៉ែត្រក្រឡា ស្ថិតនៅភូមិផ្សារលិច សង្កាត់ព្រែកព្នៅ ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ ដែលបានកំណត់ក្នុងអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ០៣

ខែកុម្ភៈ ឆ្នាំ ២០១៦ ស្តីពីការកំណត់ផ្ទៃបឹងតាមោក (បឹងកប់ស្រូវ) ទំហំ ៣ ២៣៩,៧ ហិកតា ស្ថិតក្នុងរាជធានីភ្នំពេញ ជាសម្បត្តិសាធារណៈរបស់រដ្ឋ តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984 ដូចមានផែនទីបង្ហាញទីតាំង និងតារាងនិយាមកាភ្ជាប់ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ និងប្រគល់ជាកម្មសិទ្ធិជូនគ្រួសារកងរាជអាវុធហត្ថលើផ្ទៃប្រទេសចំនួន ១៦ គ្រួសារ។

**មាត្រា ២ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៣ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ១០កើត ខែ បុស្ស ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ២០២០

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ផែនទីបង្ហាញទីតាំងដីទំហំសរុប ២៧ ៦៥៩ ម៉ែត្រក្រឡា ស្ថិតនៅភូមិផ្សារលិច សង្កាត់ព្រែកព្នៅ ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ ស្នើសុំកាត់ចេញពីផ្ទៃបឹងតាមោក (បឹងកប់ស្រូវ) កំណត់ដោយអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ០៣ ខែកុម្ភៈ ឆ្នាំ ២០១៦ ជូនគ្រួសារកងរាជអាវុធហត្ថលើផ្ទៃប្រទេស ចំនួន ១៦ គ្រួសារ




| លេខក្បាលដី | ឈ្មោះអ្នកកាន់កាប់ដី | ក្រឡាផ្ទៃដីស្ថិតក្នុងផ្ទៃបឹងតាមោក (ម៉ែត្រក្រឡា) | ក្រឡាផ្ទៃដីសរុប (ម៉ែត្រក្រឡា) |
|---|---|---|---|
| 1 | ម៉េង ឈាង | 3442 | 3442 |
| 2 | ហ៊ុ សុខហេង | 5571 | 5571 |
| 3 | វ៉ាន់ ប៊ុនឡោ | 3055 | 3055 |
| 4 | ខួន វិច្ឆ៉ា | 2156 | 2156 |
| 5 | ហ៊ីង ឃ្មុំ | 3544 | 3544 |
| 6 | សាន់ ទាំង | 1526 | 1526 |
| 7 | តាវ់ តារី | 2370 | 3727 |
| 8 | សុខា វ៉ាណែត | 1099 | 1649 |
| 9 | មុំ សុខម៉េង | 337 | 549 |
| 10 | លី ណារ | 1469 | 2602 |
| 11 | ណាង ម៉េងហុង | 457 | 1240 |
| 12 | ហុង ឈុណ្ណយ | 793 | 1102 |
| 13 | ឈាង លីដា | 463 | 647 |
| 14 | សុខា វ៉ាន់នី | 499 | 700 |
| 15 | ជុំ ចាន់ណា | 373 | 525 |
| 16 | វិឡុ ឈនវិសិដ្ឋ | 515 | 1341 |
| សរុប | | 27659 | 33376 |

**សញ្ញាសម្គាល់**

- ចំណុចនិយាមកាព្រំដីស្នើសុំកាត់ចេញពីផ្ទៃបឹងតាមោក កំណត់ដោយអនុក្រឹត្យលេខ ២០
- ដីសរុបទំហំ ២៧ ៦៥៩ ម៉ែត្រក្រឡា ស្នើសុំកាត់ចេញពីផ្ទៃបឹងតាមោកកំណត់ដោយអនុក្រឹត្យលេខ ២០
- ព្រំផ្ទៃបឹងតាមោក (បឹងកប់ស្រូវ) អនុក្រឹត្យលេខ ២០ អនក្រ ចុះថ្ងៃទី ២៣ ខែកុម្ភៈ ឆ្នាំ ២០១៦

តារាងនិយាមកាព្រំដីស្នើសុំកាត់ចេញពីផ្ទៃបឹងតាមោក កំណត់ដោយអនុក្រឹត្យលេខ ២០ អនក្រ.បក

Projection UTM, Zone 48N, Datum WGS 84.

| Point_ID | Easting(m) | Northing(m) |
|---|---|---|
| 1 | 483238.132 | 1288530.630 |
| 2 | 483232.146 | 1288553.957 |
| 3 | 483262.370 | 1288560.377 |
| 4 | 483285.442 | 1288562.811 |
| 5 | 483341.004 | 1288561.012 |
| 6 | 483349.154 | 1288559.001 |
| 7 | 483361.918 | 1288553.047 |
| 8 | 483453.413 | 1288530.194 |
| 9 | 483503.080 | 1288521.541 |
| 10 | 483542.987 | 1288516.334 |
| 11 | 483596.906 | 1288514.885 |
| 12 | 483618.003 | 1288516.123 |
| 13 | 483649.873 | 1288520.311 |
| 14 | 483659.378 | 1288522.285 |
| 15 | 483682.926 | 1288526.868 |
| 16 | 483702.696 | 1288469.112 |
| 17 | 483691.439 | 1288465.843 |
| 18 | 483711.058 | 1288444.683 |
| 19 | 483714.305 | 1288435.197 |
| 20 | 483732.972 | 1288380.662 |
| 21 | 483744.765 | 1288346.210 |
| 22 | 483741.465 | 1288346.741 |
| 23 | 483729.070 | 1288353.052 |
| 24 | 483715.995 | 1288373.075 |
| 25 | 483696.239 | 1288409.806 |
| 26 | 483685.267 | 1288417.053 |
| 27 | 483682.452 | 1288424.821 |
| 28 | 483678.945 | 1288434.186 |
| 29 | 483655.805 | 1288456.492 |
| 30 | 483652.486 | 1288469.630 |
| 31 | 483662.478 | 1288472.154 |
| 32 | 483661.331 | 1288476.691 |
| 33 | 483624.397 | 1288473.055 |
| 34 | 483548.726 | 1288464.692 |
| 35 | 483508.389 | 1288464.965 |
| 36 | 483457.852 | 1288464.053 |
| 37 | 483448.123 | 1288460.661 |
| 38 | 483445.519 | 1288460.706 |
| 39 | 483440.673 | 1288461.935 |
| 40 | 483431.246 | 1288464.081 |
| 41 | 483428.322 | 1288466.270 |
| 42 | 483418.348 | 1288479.447 |
| 43 | 483412.927 | 1288483.144 |
| 44 | 483405.458 | 1288487.156 |
| 45 | 483398.775 | 1288492.285 |
| 46 | 483380.978 | 1288496.370 |
| 47 | 483370.929 | 1288502.151 |
| 48 | 483359.462 | 1288511.140 |
| 49 | 483360.758 | 1288531.077 |
| 50 | 483275.505 | 1288534.678 |
| 51 | 483269.183 | 1288534.526 |
| 52 | 483255.287 | 1288533.708 |
| 53 | 483247.324 | 1288532.403 |
| 54 | 484114.929 | 1287860.004 |
| 55 | 484134.030 | 1287834.960 |
| 56 | 484145.248 | 1287820.252 |
| 57 | 484157.376 | 1287804.351 |
| 58 | 484166.472 | 1287792.425 |
| 59 | 484179.000 | 1287776.000 |
| 60 | 484159.206 | 1287761.178 |
| 61 | 484146.463 | 1287777.719 |
| 62 | 484137.309 | 1287789.602 |
| 63 | 484125.103 | 1287805.445 |
| 64 | 484113.813 | 1287820.101 |
| 65 | 484094.589 | 1287845.054 |